# ការស្វែងយល់អំពីការធានាឥណទាន

## ជួបជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ)




### ១. តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ យល់ឃើញដូចម្តេចចំពោះគម្រោងធានាឥណទាននៅកម្ពុជា? ហេតុអ្វីបានជាអេ អឹម ខេ ចូលរួមជាដៃគូជាមួយ CGCC?

គម្រោងធានាឥណទាន មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់អតិថិជនទាំងឡាយណា ដែលមិនមានលទ្ធភាពក្នុងការទទួលបានហិរញ្ញប្បទាន ដោយគ្មានទ្រព្យធានា។ CGCC ដើរតួរយ៉ាងសំខាន់ក្នុងការគាំទ្រដល់អាជីវកម្មក្នុងស្រុក ដើម្បីបង្កើនភាពមានការងារធ្វើ ក៏ដូចជាគាំទ្រដល់កំណើនសេដ្ឋកិច្ចកម្ពុជាទាំងមូលផងដែរ។ ជាមួយគ្នានេះ គម្រោងធានាឥណទាន បានគាំទ្រដល់បេសកកម្មរបស់ អេ អឹម ខេ ក្នុងការគាំទ្រដល់ប្រជាជនកម្ពុជា ដើម្បីទទួលបានហិរញ្ញប្បទានដោយគ្មានទ្រព្យធានា។

### ២. បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងធានាឥណទានជាមួយ CGCC និងកំពុងក្លាយជា PFI ដែលផ្តល់កម្ចីដែលមានការធានាច្រើនជាងគេមួយរបស់ CGCC តើ អេ អឹម ខេ យល់ឃើញថា គម្រោងធានាឥណទានបានផ្តល់អត្ថប្រយោជន៍ដូចម្តេចខ្លះចំពោះ អេ អឹម ខេ និងអតិថិជន?

តាមរយៈគម្រោងធានាឥណទានរបស់ CGCC អេ អឹម ខេ អាចពង្រីកការផ្តល់កម្ចីដែលមិនមានទ្រព្យធានាបានកាន់តែច្រើនឡើងៗ។ បើគ្មាន CGCC ទេ យើងក៏មិនមានទំនុកចិត្ត ក្នុងការផ្តល់កម្ចីយ៉ាងច្រើនបែបនេះដែរ ដោយសារយើងត្រូវពិចារណាយ៉ាងល្អិតលើកម្ចីដែលគ្មានទ្រព្យធានា ពិសេសលើហានិភ័យអាជីវកម្មក្ស័យធន មិនមានលទ្ធភាពសងត្រលប់ប្រាក់កម្ចី។ សម្រាប់អតិថិជនពួកគាត់អាចរីករាយនឹងការគាំទ្រផ្នែកហិរញ្ញប្បទានពី អេ អឹម ខេ ដែលអាចបំពេញសេចក្តីត្រូវការរបស់ពួកគាត់ដើម្បីកំណើនអាជីវកម្ម ដោយពួកគាត់មិនចាំបាច់ព្រួយបារម្ភច្រើនពេកទៅលើតម្រូវការទ្រព្យធានា។

### ៣. តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ យល់យ៉ាងដូចម្តេចចំពោះការធានាឥណទានជាកញ្ចប់ក្រោមការធានារបស់ CGCC? តើគម្រោងនេះអាចផ្តល់អត្ថប្រយោជន៍យ៉ាងណាខ្លះដល់ អេ អឹម ខេ ក្នុងការបញ្ចេញកម្ចីដែលខ្វះទ្រព្យធានា?

ពិតណាស់ ចំពោះ អេ អឹម ខេ គម្រោងធានាឥណទានជាកញ្ចប់នេះ គឺជាគំនិតផ្តួចផ្តើមដ៏ល្អ ព្រោះថាវានឹងធ្វើឱ្យប្រសើរឡើងនូវពេលវេលាដំណើរការ និងបន្ទុកការងារ ដែលជះឥទ្ធិពលដល់ដំណើរការក្នុងការស្នើសុំប្រាក់កម្ចីទាំងមូល។ យ៉ាងណាក៏ដោយ យើងចង់ឃើញកម្រៃធានាឥណទានទាប សម្រាប់គម្រោងនេះបើប្រៀបធៀបទៅនឹងគម្រោងបច្ចុប្បន្ន។

### ៤.ដោយមើលឃើញថា មួយរយៈចុងក្រោយនេះ អេ អឹម ខេ បាននិងកំពុងតែបន្តបញ្ចេញឥណទានដែលគ្មានទ្រព្យធានាក្រោមការធានាពី CGCC ដល់អាជីវកម្មកាន់តែច្រើន ដូច្នេះ តើ អេ អឹម ខេ មានយុទ្ធសាស្ត្រ ឬផែនការដូចម្តេច ដើម្បីបង្កើនការប្រើប្រាស់ការធានាឥណទានឱ្យកាន់តែច្រើនទៀត នៅទូទាំងប្រទេសកម្ពុជា នាឆ្នាំ២០២៣ ខាងមុខនេះ?

ពួកយើង (អេ អឹម ខេ) នឹងបន្តផ្តោតលើការបំពេញតម្រូវការរបស់អតិថិជនរបស់យើងក្នុងគ្រប់វិស័យ។ លើសពីនេះ ពួកយើងនឹងផ្តោតសំខាន់លើអាជីវកម្មពាក់ព័ន្ធនឹងថាមពលកកើតឡើងវិញ (renewable energy) និងវិស័យកសិកម្ម។

### ៥. ដោយសារតែប្រធានបទនៃការធានាឥណទាននៅតែជារឿងថ្មីនៅឡើយសម្រាប់កម្ពុជា តើ អេ អឹម ខេ និង CGCC គួរតែបន្តធ្វើអ្វីខ្លះទៀត ដើម្បីលើកកម្ពស់ការយល់ដឹងនៃការធានាឥណទានសម្រាប់អតិថិជននាឆ្នាំ២០២៣ខាងមុខនេះ?

វាជាការល្អប្រសិនបើ CGCC និង AMK អាចចូលរួមសហប្រតិបត្តិជាមួយគ្នាធ្វើកម្មវិធីសិក្ខាសាលាជាបន្តបន្ទាប់ ដើម្បីបង្កើនការយល់ដឹងអំពីភាពជាដៃគូនេះដល់សហគ្រាសធុនតូច និងមធ្យម តាមរយៈសមាគមឯកជន និងអាជីវកម្មនៅកម្ពុជា។